# Course: Applied Business Statistics

Week 1

Chapter 1. Numerical Descriptive Measures (1)

Lecturer: Udam Prang, PhD, MEd

# មុខវិជ្ជា៖ ស្ថិតិធុរកិច្ចអនុវត្តន៍

## សប្តាហ៍ទី១

## មេរៀនទី១. រង្វាស់ពណ៌នាចំនួន (១)

គ្រូបង្រៀន៖ បណ្ឌិត ប្រាំង ឧត្តម

# មាតិកា

១. រំលឹកពីប្រភេទសំណុំទិន្នន័យ (Review on Data Types)

២. រង្វាស់ទីតាំងកណ្តាលនៃសំណុំទិន្នន័យ (Measures of Central Locations)

៣. រង្វាស់ភាពរាយប៉ាយនៃសំណុំទិន្នន័យ (Measures of Dispersion)

# ១. រំលឹកពីប្រភេទសំណុំទិន្នន័យ

# មធ្យោបាយចាត់ថ្នាក់សំណុំទិន្នន័យ

សំណុំទិន្នន័យអាចត្រូវបានចាត់ថ្នាក់តាមមធ្យោបាយច្រើនយ៉ាង៖

- មធ្យោបាយទី១៖ ទិន្នន័យសាកល (Population Data) និង ទិន្នន័យគំរូ (Sample Data)
- មធ្យោបាយទី២៖ ទិន្នន័យចំរុះផ្នែក (Cross-sectional Data) និង ទិន្នន័យពេលវេលាជាសេរី (Time-series Data)
- មធ្យោបាយទី៣៖ ទិន្នន័យរៀបរយ (Structured Data) និង ទិន្នន័យមិនរៀបរយ (Unstructured Data)
- មធ្យោបាយទី៤៖ ទិន្នន័យបរិមាណ (Quantitative Data) និង ទិន្នន័យគុណភាព (Qualitative Data)
- មធ្យោបាយទី៥៖ ទិន្នន័យដែលមិនទាន់ត្រូវបានរៀបចំ (Ungrouped Data or Raw Data) និង ទិន្នន័យដែលត្រូវបានរៀបចំរួចរាល់ (Grouped Data)

© 2023 Udam Prang

# មធ្យោបាយទី១

## ទិន្នន័យសាកល

ទិន្នន័យសាកល បានមកពីការធ្វើជំរឿន។ ឧទាហរណ៍. ក្នុងក្រុមហ៊ុនមួយ មានបុគ្គលិក ៥០ នាក់។ ការធ្វើជំរឿនក្នុងក្រុមហ៊ុន គឺ ការប្រមូលព័ត៌មាន ឬ ស្រង់មតិពីបុគ្គលិកទាំង ៥០ នាក់។ ទិន្នន័យដែលទទួលបាន គឺ ទិន្នន័យសាកល។

## ទិន្នន័យគំរូ

ទិន្នន័យគំរូ បានមកពីការស្រាវជ្រាវលើប៉ាន់គំរូ (Sample) ដែលជាផ្នែកមួយនៃសាកលស្ថិតិ (Population)។ ឧទាហរណ៍. ក្នុងក្រុមហ៊ុនមួយ មានបុគ្គលិក ៥០ នាក់។ ការស្រាវជ្រាវលើប៉ាន់គំរូ គឺ ការស្រង់មតិពីបុគ្គលិកមួយចំនួនប៉ុណ្ណោះ (ដែលចំនួននេះ អាចប្រែប្រួលតាមការកំណត់របស់អ្នកស្រាវជ្រាវ)។ ទិន្នន័យដែលទទួលបាន គឺ ទិន្នន័យគំរូ។

© 2023 Udam Prang

# មធ្យោបាយទី២

## ទិន្នន័យចំរុះផ្នែក

| ប្រទេស | កំណើន GDP |
|---|---|
| ប្រទេស ក | ៧% |
| ប្រទេស ខ | ៥% |
| ប្រទេស គ | ៦% |

## ទិន្នន័យពេលវេលាជាសេរី

| ប្រទេស | ឆ្នាំ | កំណើន GDP |
|---|---|---|
| ប្រទេស ក | ២០០១ | ៧% |
| | ២០០២ | ៦% |
| | ២០០៣ | ៧% |
| | ២០០៤ | ៨% |
| | ២០០៥ | ៧% |
| | ២០០៦ | ៦% |
| | ២០០៧ | ៦% |
| | ២០០៨ | ៥% |
| | ២០០៩ | ៦% |

# មធ្យោបាយទី៣

## ទិន្នន័យរៀបរយ

| ប្រទេស | កំណើន GDP |
|---|---|
| ប្រទេស ក | ៧% |
| ប្រទេស ខ | ៥% |
| ប្រទេស គ | ៦% |

## ទិន្នន័យមិនរៀបរយ

"វាពិតជាពិបាកខ្លាំងណាស់ក្នុងការប្រឈមមុខជាមួយអតិថិជនទាំងនោះ។ ជាទូទៅ ខ្ញុំជ្រើសរើសស្របតាមពួកគាត់ ជាជាង ប្រកែកយកឈ្នះ"

អ្នកចូលរួមស្រាវជ្រាវទីមួយ

# មធ្យោបាយទី៤

## ទិន្នន័យបរិមាណ

| ប្រទេស | កំណើន GDP |
| --- | --- |
| ប្រទេស ក | ៧% |
| ប្រទេស ខ | ៥% |
| ប្រទេស គ | ៦% |

## ទិន្នន័យគុណភាព

"វាពិតជាពិបាកខ្លាំងណាស់ក្នុងការប្រឈមមុខជាមួយអតិថិជនទាំងនោះ។ ជាទូទៅ ខ្ញុំជ្រើសរើសស្របតាមពួកគាត់ ជាជាង ប្រកែកយកឈ្នះ"

អ្នកចូលរួមស្រាវជ្រាវទីមួយ

# មធ្យោបាយទី៥

ទិន្នន័យដែលមិនទាន់ត្រូវបានរៀបចំ

២, ៣, ៣, ៥, ៦, ៧, ៨, ២, ៣, ៥, ១, ៥, ៦, ៧, ៨, ១, ២, ៣, ៤, ៤

ទិន្នន័យដែលត្រូវបានរៀបចំរួចរាល់

| ចំណាត់ថ្នាក់ | ប្រេកង់ (Frequency) |
|---|---|
| លេខ ១ | ៣ |
| លេខ ២ | ៣ |
| លេខ ៣ | ៤ |
| លេខ ៤ | ២ |
| លេខ ៥ | ៣ |
| លេខ ៦ | ២ |
| លេខ ៧ | ២ |
| លេខ ៨ | ១ |
| លេខ ៩ | ០ |

© 2023 Udam Prang

# ២. រង្វាស់ទីតាំងកណ្ដាលនៃសំណុំទិន្នន័យ

មធ្យម (Mean) | មេដ្យាន (Median) | ម៉ូដ (Mode)

© 2023 Udam Prang

# រង្វាស់ទីតាំងកណ្ដាលនៃសំណុំទិន្នន័យ

ការប្រើប្រាស់រង្វាស់ទីតាំងកណ្ដាល ជាវិធីសាស្ត្រមួយក្នុងការសង្ខេបទិន្នន័យ។

រង្វាស់ទីតាំងកណ្ដាលនៃសំណុំទិន្នន័យ មាន ០៣ សំខាន់ៗ គឺ៖

- មធ្យម (Mean)
- មេដ្យាន (Median)
- ម៉ូដ (Mode)

© 2023 Udam Prang

# មធ្យម

មធ្យម មានពីរប្រភេទ គឺ៖ មធ្យមនព្វន្ត និង មធ្យមទម្ងន់

- មធ្យមនព្វន្ត ត្រូវបានប្រើប្រាស់ នៅពេលដែលតម្លៃនីមួយៗ នៅក្នុងសំណុំទិន្នន័យមានទម្ងន់ស្មើគ្នា។ មធ្យមនព្វន្ត ជារង្វាស់ពេញនិយម ប៉ុន្តែតម្លៃមធ្យមនព្វន្ត រងឥទ្ធិពលដោយតម្លៃអច្ឆន្តបរមា (Outliers) ដែលជាតម្លៃតូចខ្លាំងឬធំខ្លាំងហួសហេតុបើធៀបទៅនឹងតម្លៃដទៃទៀតនៅក្នុងសំណុំទិន្នន័យ។
- មធ្យមទម្ងន់ ត្រូវបានប្រើប្រាស់ នៅពេលដែលតម្លៃនីមួយៗ នៅក្នុងសំណុំទិន្នន័យមានទម្ងន់មិនស្មើគ្នា។

© 2023 Udam Prang

# មធ្យមនព្វន្ត

សម្រាប់សំណុំទិន្នន័យគំរូ, មធ្យមនព្វន្ត (តាងដោយ $\bar{x}$) មានរូបមន្តដូចខាងក្រោម៖

$$\bar{x} = \frac{\sum_{i=1}^{n} x_i}{n} = \frac{x_1 + x_2 + \cdots + x_n}{n}$$

ដែល $x_1, x_2, \ldots, x_n$ គឺជាតម្លៃនីមួយៗ នៅក្នុងសំណុំទិន្នន័យ ហើយ n គឺជាទំហំប៉ាន់គំរូ (Sample Sizes)។

# មធ្យមនព្វន្ត

សម្រាប់សំណុំទិន្នន័យសាកល, មធ្យមនព្វន្ត (តាងដោយ $\mu$) មានរូបមន្តដូចខាងក្រោម៖

$$\mu = \frac{\sum_{i=1}^{N} x_i}{N} = \frac{x_1 + x_2 + \cdots + x_N}{N}$$

ដែល $x_1$, $x_2$, …, $x_N$ គឺជាតម្លៃនីមួយៗ នៅក្នុងសំណុំទិន្នន័យ ហើយ N គឺជាទំហំសាកលស្ថិតិ (Population Sizes)។

# មធ្យមនព្វន្ត

**ឧទាហរណ៍.** សំណុំទិន្នន័យគំរូមួយ មានតម្លៃដូចតទៅ៖ ១, ២, ៤, ៥, ៦, ៧, ២, ៤។

តើមធ្យមនៃសំណុំទិន្នន័យនេះ ស្មើនឹងប៉ុន្មាន?

**ដំណោះស្រាយ**

តាមរូបមន្តមធ្យមនព្វន្ត, យើងបាន៖

$$\bar{x} = \frac{\sum_{i=1}^{n} x_i}{n} = \frac{x_1 + x_2 + \cdots + x_n}{n} = \frac{១+២+៤+៥+៦+៧+២+៤}{៨} = ៣,៨៧៥$$

# មធ្យមទម្ងន់

សម្រាប់សំណុំទិន្នន័យគំរូ, មធ្យមទម្ងន់(តាងដោយ $\bar{x}$) មានរូបមន្តដូចខាងក្រោម៖

$$\bar{x} = \sum_{i=1}^{n} w_i x_i = w_1 x_1 + w_2 x_2 + \cdots + w_n x_n$$

ដែល $w_1, w_2, \ldots, w_n$ គឺជាទម្ងន់នៃតម្លៃ $x_1, x_2, \ldots, x_n$ រៀងគ្នា។ ហើយផលបូកនៃទម្ងន់ទាំងអស់ត្រូវស្មើនឹងមួយ ពោលគឺ៖ $w_1 + w_2 + \ldots + w_n = 1$។

© 2023 Udam Prang Not For Citation | For Educational Purposes Only

# មធ្យមទម្ងន់

សម្រាប់សំណុំទិន្នន័យសាកល, មធ្យមទម្ងន់(តាងដោយ $\mu$) មានរូបមន្តដូចខាងក្រោម៖

$$\mu = \sum_{i=1}^{N} w_i x_i = w_1 x_1 + w_2 x_2 + \cdots + w_n x_N$$

ដែល $w_1, w_2, \ldots, w_N$ គឺជាទម្ងន់នៃតម្លៃ $x_1, x_2, \ldots, x_N$ រៀងគ្នា។ ហើយផលបូកនៃទម្ងន់ទាំងអស់ត្រូវស្មើនឹងមួយ ពោលគឺ៖ $w_1 + w_2 + \ldots + w_N = 1$។

# មធ្យមទម្ងន់

**ឧទាហរណ៍.** ផែនការសកម្មភាពប្រចាំសប្ដាហ៍របស់បុគ្គលិកម្នាក់ មាន បី សកម្មភាព។ អាទិភាពនៃសកម្មភាពទាំងបី ត្រូវបានផ្ដល់ជាទម្ងន់ដូចតទៅ៖

- សកម្មភាពទីមួយ មានទម្ងន់ ៥0%
- សកម្មភាពទីពីរ មានទម្ងន់ ៣0%
- សកម្មភាពទីបី មានទម្ងន់ ២0%

សកម្មភាពណាដែលមានទម្ងន់ខ្ពស់ជាងគេ ជាសកម្មភាពសំខាន់ជាងគេ។ បន្ទាប់ពីបញ្ចប់សប្ដាហ៍, បុគ្គលិកនោះ វាយតម្លៃពីវឌ្ឍនភាពផែនការសកម្មភាពរបស់ខ្លួន (ដូចក្នុងតារាងនៅស្លាយបន្ទាប់)។

© 2023 Udam Prang

# មធ្យមទម្ងន់

| ផែនការសកម្មភាព | ពិន្ទុវឌ្ឍនភាពការងារ |
| --- | --- |
| សកម្មភាពទីមួយ | ៨0% |
| សកម្មភាពទីពីរ | ៧0% |
| សកម្មភាពទីបី | ៩0% |

តើពិន្ទុវឌ្ឍនភាពការងាររបស់គាត់ ជាមធ្យម ស្មើប៉ុន្មានភាគរយ?

**ចម្លើយ៖** ពិន្ទុវឌ្ឍនភាពការងាររបស់គាត់ជាមធ្យមស្មើនឹង 0,៧៩ ឬ ៧៩%។

© 2023 Udam Prang

# មេដ្យាន

មេដ្យាន គឺជា តម្លៃដែលស្ថិតនៅទីតាំងកណ្ដាលនៃសំណុំទិន្នន័យ។ ជាទូទៅ សម្រាប់សំណុំទិន្នន័យគំរូ មេដ្យានតាងដោយអក្សរ $\tilde{x}$។

ដើម្បីស្វែងរកតម្លៃមេដ្យាន យើងត្រូវរៀបតម្លៃនីមួយៗនៅក្នុងសំណុំទិន្នន័យតាមលំដាប់ពីទាបទៅខ្ពស់។

- ប្រសិនបើទំហំគំរូ ឬទំហំសាកលស្ថិតិជាចំនួនសេស តម្លៃមេដ្យាន គឺជា តម្លៃដែលស្ថិតនៅទីតាំងកណ្ដាលនៃសំណុំទិន្នន័យ។
- ប្រសិនបើទំហំគំរូ ឬទំហំសាកលស្ថិតិជាចំនួនគូ តម្លៃដែលស្ថិតនៅទីតាំងកណ្ដាលរបស់សំណុំទិន្នន័យមានពីរ។ មេដ្យាន គឺជា មធ្យមនព្វន្តនៃតម្លៃទាំងពីរ។

# មេដ្យាន

**ឧទាហរណ៍.** សំណុំទិន្នន័យគំរូមួយ មានតម្លៃដូចតទៅ៖ ១, ២, ៤, ៥, ៦, ៧, ២, ៤។

តើមេដ្យាននៃសំណុំទិន្នន័យនេះ ស្មើនឹងប៉ុន្មាន?

**ដំណោះស្រាយ**

រៀបលំដាប់ពីទាបទៅខ្ពស់៖ ១, ២, ២, ៤, ៤, ៥, ៦, ៧

តម្លៃដែលស្ថិតនៅទីតាំងកណ្តាលមានពីរគឺ៖ ៤, ៤

ដូច្នេះ មេដ្យានស្មើនឹង ៤ ដែលជាតម្លៃមធ្យមនព្វន្តនៃតម្លៃទាំងពីរ។

© 2023 Udam Prang
Not For Citation | For Educational Purposes Only

# ម៉ូដ

ម៉ូដ គឺជា តម្លៃដែលកើតឡើងញឹកញាប់ជាងគេក្នុងសំណុំទិន្នន័យ។ សំណុំទិន្នន័យមួយអាចម៉ូដច្រើនជាងមួយ។

**ឧទាហរណ៍.** សំណុំទិន្នន័យគំរូមួយ មានតម្លៃដូចតទៅ៖ ១, ២, ៤, ៥, ៦, ៧, ២, ៤។

តើម៉ូដនៃសំណុំទិន្នន័យនេះ ស្មើនឹងប៉ុន្មាន?

**ដំណោះស្រាយ**

សំណុំទិន្នន័យនេះ មានម៉ូដចំនួនពីរ គឺ៖ ២ និង ៤ ដោយសារតម្លៃទាំងពីរនេះកើតឡើងញឹកញាប់ជាងគេ។

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

ក្នុងការអនុវត្តជាក់ស្តែង, សំណុំទិន្នន័យមានទំហំធំ ដែលទាមទារឱ្យអ្នកវិភាគត្រូវរៀបចំទិន្នន័យជាតារាងបំណែងចែកប្រេកង់ (Frequency Distribution Table)។

ឧទាហរណ៍៖

| **ក្រុមអាយុ** | **ប្រេកង់** (តាងដោយ $f_i$) |
|---|---|
| ក្រោម ២៦ ឆ្នាំ | ១ |
| ២៦ ឆ្នាំ ដល់ ៣០ ឆ្នាំ | ៨ |
| ៣១ ឆ្នាំ ដល់ ៣៥ ឆ្នាំ | ១១ |
| ៣៦ ឆ្នាំ ដល់ ៤០ ឆ្នាំ | ៥ |
| លើស ៤០ ឆ្នាំ | ៥ |
| សរុប | ៣០ |

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

សម្រាប់សំណុំទិន្នន័យដែលបង្ហាញជាតារាងបំណែងចែកប្រេកង់ដូចខាងលើ, រូបមន្ត មធ្យមនព្វន្តត្រូវបានកែសម្រួលដូចខាងក្រោម៖

**សម្រាប់សំណុំទិន្នន័យគំរូ៖** $\bar{x} = \frac{\sum_{i=1}^{n} m_i f_i}{n}$

**សម្រាប់សំណុំទិន្នន័យសាកល៖** $\mu = \frac{\sum_{i=1}^{N} m_i f_i}{N}$

ក្នុងនោះ, $m_i$ គឺជាចំណុចកណ្តាលនៃថ្នាក់ទី i ហើយ $f_i$ គឺជាប្រេកង់នៃថ្នាក់ទី i។

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

ដោយឡែក ការគណនាតម្លៃមេដ្យាន និងតម្លៃម៉ូដ មានពីរដំណាក់កាល៖

- ដំណាក់កាលទីមួយ៖ ត្រូវកំណត់ថ្នាក់ដែលមានមេដ្យាន និងម៉ូដ (តាមនិយមន័យរបស់មេដ្យាន និងម៉ូដ ដែលបានបង្ហាញពីខាងលើ)។
- ដំណាក់កាលទីពីរ៖ គណនាតាមរូបមន្ត (នៅក្នុងស្លាយបន្ទាប់)។

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

រូបមន្តមេដ្យាន៖

$$\tilde{x} = l + w\left(\frac{\frac{n}{2} - cf}{f}\right)$$

ក្នុងនោះ l ជាតម្លៃទាបបំផុតនៃថ្នាក់មេដ្យាន, w ជាចន្លោះថ្នាក់ (Class Width), f ជាប្រេកង់នៃថ្នាក់មេដ្យាន, និង cf ជាប្រេកង់កើននៃថ្នាក់ដែលស្ថិតនៅខាងលើផ្ទាល់នឹងថ្នាក់មេដ្យាន។

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

រូបមន្តម៉ូដ៖

$$Mode = l + w\left(\frac{f_m - f_1}{(f_m - f_1) + (f_m - f_2)}\right)$$

ក្នុងនោះ, $l$ ជាតម្លៃទាបបំផុតនៃថ្នាក់ម៉ូដ, $w$ ជាចន្លោះថ្នាក់, $f_m$ ជាប្រេកង់នៃថ្នាក់ម៉ូដ, $f_1$ ជាប្រេកង់នៃថ្នាក់ដែលស្ថិតនៅខាងលើផ្ទាល់នឹងថ្នាក់ម៉ូដ, ហើយ $f_2$ ជាប្រេកង់នៃថ្នាក់ដែលស្ថិតនៅខាងក្រោមផ្ទាល់នឹងថ្នាក់ម៉ូដ។

© 2023 Udam Prang

# ការអនុវត្តលើតារាងបំណែងចែកប្រេកង់

ឧទាហរណ៍. ចូរកំណត់តម្លៃមធ្យម មេដ្យាន និងម៉ូដ សម្រាប់សំណុំទិន្នន័យខាងក្រោម៖

| ក្រុមអាយុ | ប្រេកង់ |
|---|---|
| ក្រោម ២៦ ឆ្នាំ | ១ |
| ២៦ ឆ្នាំ ដល់ ៣០ ឆ្នាំ | ៨ |
| ៣១ ឆ្នាំ ដល់ ៣៥ ឆ្នាំ | ១១ |
| ៣៦ ឆ្នាំ ដល់ ៤០ ឆ្នាំ | ៥ |
| លើស ៤០ ឆ្នាំ | ៥ |
| សរុប | ៣០ |

**ចម្លើយ៖** មធ្យម = ៣៣,៨៣ ឆ្នាំ | មេដ្យាន = ៣៣,៧២ ឆ្នាំ | ម៉ូដ = ៣២,៦៦ ឆ្នាំ។

© 2023 Udam Prang

# ៣. រង្វាស់តាពរាយប៉ាយនៃសំណុំទិន្នន័យ

វ៉ារ្យ៉ង់ (Variance) | គម្លាតស្តង់ដា (Standard Deviation) | មេគុណបម្រែបម្រួល (Coefficient of Variation)

# រង្វាស់ភាពរាយប៉ាយនៃសំណុំទិន្នន័យ

ការប្រើប្រាស់រង្វាស់ភាពរាយប៉ាយ គឺជាវិធីសាស្ត្រមួយទៀតក្នុងការសង្ខេបសំណុំទិន្នន័យ។

រង្វាស់ភាពរាយប៉ាយមានច្រើន តែយើងនឹងផ្តោតទៅលើរង្វាស់តែបីប៉ុណ្ណោះ ដែលជារង្វាស់ពេញនិយមជាងគេ។ នោះគឺ៖

- វ៉ារ្យ៉ង់ (Variance)
- គម្លាតស្តង់ដា (Standard Deviation)
- មេគុណបម្រែបម្រួល (Coefficient of Variation)

# វ៉ារ្យ៉ង់

សម្រាប់សំណុំទិន្នន័យគំរូ វ៉ារ្យ៉ង់តាងដោយ $s^2$ និងមានរូបមន្តដូចខាងក្រោម៖

$$s^2 = \frac{\sum_{i=1}^{n}(x_i - \bar{x})^2}{n-1}$$

សម្រាប់សំណុំទិន្នន័យសាកល វ៉ារ្យ៉ង់តាងដោយ $\sigma^2$ និងមានរូបមន្តដូចខាងក្រោម៖

$$\sigma^2 = \frac{\sum_{i=1}^{n}(x_i - \mu)^2}{N}$$

© 2023 Udam Prang

# គម្លាតស្តង់ដា

គម្លាតស្តង់ដា ទាញចេញពី វ៉ារ្យ៉ង់។

សម្រាប់សំណុំទិន្នន័យគំរូ គម្លាតស្តង់ដាតាងដោយ s និងមានរូបមន្តដូចខាងក្រោម៖

$$s = \sqrt{s^2} = \sqrt{\frac{\sum_{i=1}^{n}(x_i - \bar{x})^2}{n-1}}$$

សម្រាប់សំណុំទិន្នន័យសាកល គម្លាតស្តង់ដាតាងដោយ σ និងមានរូបមន្តដូចខាងក្រោម៖

$$\sigma = \sqrt{\sigma^2} = \sqrt{\frac{\sum_{i=1}^{N}(x_i - \mu)^2}{N-1}}$$

© 2023 Udam Prang Not For Citation | For Educational Purposes Only

# មេគុណបម្រែបម្រួល

មេគុណបម្រែបម្រួល ទាញចេញមកពី គម្លាតស្តង់ដា។ ផ្ទុយពីតម្លៃគម្លាតស្តង់ដាដែលមានឯកតា តម្លៃមេគុណបម្រែបម្រួលមិនមានឯកតានោះទេ។

ជាទូទៅ មេគុណបម្រែបម្រួល តាងដោយអក្សរ CV។

សម្រាប់សំណុំទិន្នន័យគំរូ, $CV = \frac{s}{\bar{x}}$

សម្រាប់សំណុំទិន្នន័យសាកល, $CV = \frac{\sigma}{\mu}$

© 2023 Udam Prang

# ឧទាហរណ៍

តារាងនេះបង្ហាញពិន្ទុមុខវិជ្ជាស្ថិតិធុរកិច្ចរបស់និស្សិតនៅក្នុងថ្នាក់មួយ។

ចូរគណនាវ៉ារ្យ៉ង់, គម្លាតស្តង់ដា និង មេគុណបម្រែបម្រួលដោយផ្អែកលើសំណុំទិន្នន័យក្នុងតារាងនេះ។

**ចម្លើយ៖** វ៉ារ្យ៉ង់ស្មើនឹង ៨១,០៥ ពិន្ទុ | គម្លាតស្តង់ដាស្មើនឹង ៩ ពិន្ទុ | មេគុណបម្រែបម្រួលស្មើនឹង ០,១៣។

| និស្សិត | ពិន្ទុ |
|---|---|
| និស្សិតទី១ | ៦០ |
| និស្សិតទី២ | ៧០ |
| និស្សិតទី៣ | ៦៥ |
| និស្សិតទី៤ | ៧៥ |
| និស្សិតទី៥ | ៨០ |
| និស្សិតទី៦ | ៨៥ |
| និស្សិតទី៧ | ៧៧ |
| និស្សិតទី៨ | ៦៥ |
| និស្សិតទី៩ | ៧៨ |
| និស្សិតទី១០ | ៩០ |

# បញ្ចប់មេរៀនត្រឹមនេះ!

នៅសប្តាហ៍បន្ទាប់ យើងនឹងសិក្សាពីរង្វាស់ទីតាំងធៀប និងរង្វាស់ទំនាក់ទំនង។

© 2023 Udam Prang
Not For Citation | For Educational Purposes Only